# ចិញ្ចឹមចង្រិតលក់ និងប្រើជាចំណីសត្វ

អ្នកខ្លះទៅគាត់សើច បើបានឮអ្នកណាម្នាក់និយាយថា ចង់ចិញ្ចឹមចង្រិតលក់ និងធ្វើជាមុខរបរ ។ ទោះបីអ្នកនោះគាត់សើចដោយហួសចិត្ត ដោយចំអក ដោយនឹកស្មានមិនដល់ ក៏ដោយ តែមុខរបរនេះ វាកំពុងកាក់កប និងវាពិតជាអាចឱ្យគេរកចំណូលបានច្រើនគួរសមដែរ បើសិនជាគេអាចធ្វើវាបានដោយត្រឹមត្រូវ។



ជាធម្មតាចង្រិត វាជាសត្វល្អិតម្យ៉ាងដែលរស់នៅតាមព្រៃ តាមភូមិស្រុក ក្នុងដីចំការជាដើម ។ ដូចតួយ៉ាងនៅខេត្តកំពង់ធំ ឱ្យតែដល់ដើមរដូវវស្សម្តងៗ ហ្វូងចង្រិតរាប់លានក្បាល ហើរចេញមកព្រោងព្រាត បង្កើតបានជាមុខរបរមួយដល់អ្នកដែល មានលទ្ធធ្វើកន្លែងដើម្បីចាប់វាយកទៅលក់ នៅម្តុំគល់ស្ពានកំពង់ធំ និងនៅតាមទីកន្លែងនានា ។

តែរដូវវស្សាឆ្នាំកន្លងទៅនេះ គេមិនសូវឃើញមានចង្រិតចុះច្រើន ដូចឆ្នាំមុនៗឡើយ ព្រោះវាពាយអស់ទៅ ដោយសារយើងបានចាប់វាដោយប្រើនុយភ្លើងងអំពូល បណ្តាលឱ្យវាថយចំនួនបន្តពូជ ។

សព្វថ្ងៃនេះតម្រូវការចង្រិតមានច្រើនគួរសមដែរ ព្រោះចង្រិតមានតែខែវស្សា ដែលសម្បូរណ៍ ឯខែប្រាំងវិញវាមិនមានទេ ជាហេតុធ្វើឱ្យអ្នកប្រកបរបរចិញ្ចឹមចង្រិតរកកម្រៃបានច្រើនគួរសម ជាពិសេសអ្នកប្រករបរនេះនៅបន្ទាយមានជ័យ និអ្នកនៅជិតព្រំដែនកម្ពុជាថៃ ។

តាមការពិត, មានតែចង្រិតចំនួនពីរប្រភេទប៉ុណ្ណោះ ដែលគេនិយមចូលចិត្ត ទិញមកបរិភោគ និងយកមកលក់នៅក្នុងទីផ្សារ ទាំងក្នុងប្រទេសនិងនាំចេញទៅប្រទេសថៃ គឺ ៖

១) ចង្រិតដូង

២) ចង្រិតក្រហម

ក្នុងចំណោមចង្រិតទាំងពីរប្រភេទខាងលើនេះ មានតែប្រភេទចង្រិតដូង មួយប៉ុណ្ណោះ ដែលគេនិយមបរិភោគនិងឱ្យតម្លៃច្រើនជាងចង្រិតដទៃ ។ ចំណែកចង្រិតក្រហមវិញ វាមានរូបរាងតូចជាង តែអ្នកបរិភោគខ្លះយល់ថាវាមានរសជាតិឆ្ងាញ់ និងងាយស្រួលបរិភោគជាង ។

ដើម្បីធ្វើមុខរបរនេះ អ្នកចិញ្ចឹមត្រូវមានដើមទុនច្រើនគួរសម ព្រោះត្រូវធ្វើរណ្ដៅធំៗពីស៊ីម៉ង់ដ៍ មួយវិញទៀតនោះ គេត្រូវធ្វើរោងគ្របពីលើរណ្ដៅនោះ ដើម្បីការពារកំដៅនិងត្រូវមានប្រាក់សម្រាប់ទិញ គ្រឿងសម្ភារៈមួយចំនួនផងដែរ ។



ខាងក្រោមនេះគឺជាការតម្រូវនិងវិធីនៃការចិញ្ចឹមចង្រិត តាមគ្រួសារ ៖

## រណ្ដៅចិញ្ចឹមចង្រិត

រណ្ដៅត្រូវធ្វើទទឹង ៣ ម បណ្ដោយ ៥ម ជម្រៅ ៧0 ទៅ ១០០ សង្ទីម៉ែត្រ យើងអាចធ្វើចំនួនរណ្ដៅតិចឬច្រើនអាស្រ័យទៅលើបំណងនិងធនធានដែលមានដើម្បីធ្វើជារបរបានយើងត្រូវធ្វើយ៉ាងហោចណាស់ចំនួន ១ រណ្ដៅដែរ ទើបសមល្មម (ទោះចំនួនរណ្ដៅតិចក៏មិនអីដែរ តែ វាខាតពេលនិងអាចរកកម្រៃបានតិចជាង)

ត្រូវរៀបឥដ្ឋរួចបូកស៊ីម៉ងដ៍ បើមិនបានបូកស៊ីម៉ងដ៍ក៏មិនអីដែរ តែត្រូវភ្ជិតឬបៀកឱ្យស្មើ កុំឱ្យមានសល់ប្រហោងសូម្បីតូចមួយក៏ដោយ ក៏មិនត្រូវ
ឱ្យមានដែរ ។

រោងសម្រាប់គ្របពីលើរណ្ដៅ ត្រូវមានកំពស់ពីដីចំនួន៣ម៉ែត្រ ទៅ ៤ម៉ែត្រ ដើម្បីឱ្យមានខ្យល់ចេញចូលល្អមួយទៀតនោះគឺដើម្បីកាត់បន្ថយកំដៅកុំឱ្យក្ដៅខ្លាំងពេក នៅកងរដូវប្រាំង។



- ត្រូវទៅទិញពូជចង្រិតនៅ ភូមិប្រជាធម្ម សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួនមួយរយ ទៅបីរយចាន ។
- ពងមួយចានតម្លៃ ១៣០០០រៀល ទៅ ១៥០០០រៀល (ជួនកាលអាចថោកជាងនេះ បើទិញច្រើន)
- ត្រូវទិញប្រអប់ក្រដាសដាក់ពងមាន់ខ្នាតធំ ឱ្យបានច្រើនសម្រាប់ធ្វើជាកន្លែងឱ្យវារស់នៅជាពិសេសគឺសម្រាប់កូនចង្រិត
- ដាក់អេប៉ុងថ្មីមួយផ្សើមដោយទឹក ឬចានសំប៉ែត (ចាស់ក៏បាន) ដាក់ទឹកបន្តិច រួច ចាក់ទឹកផ្សើមក្រដាស់នោះឱ្យជោកសម្រាប់ឱ្យវាបឺតយកសំណើម ដែលវាត្រូវការ ។

តែបើយើងគ្មានលទ្ធភាពអាចប្រើត្រឹមស្លឹកកណ្តុបស្លឹកត្នោតក៏បានដែរ ដោយដាក់ស្លឹកនោះតម្រៀបវាបញ្ឈរជាប់ៗគ្នាឱ្យចុងស្លឹកធ្លាក់ដល់ក្រោម (កុំប្រើស្បូវកណ្តុប) យើងអាចប្រើប្រអប់ឬកេះក្រដាស់កាត់ជាបន្ទះផ្ទាំងធំល្មមដាក់តម្រៀបគ្នាក៏អាចប្រើការបានដែរ ក្រៅពីនេះយើងក៏អាចប្រើមែកឈើក៏បាន។ រយេៈពេលនៃការចិញ្ចឹម និងការទទួលផល ៖ បន្ទាប់ពីបានពងចង្រិតហើយ យើងត្រូវ ដាក់ពងចង្រិតនោះនៅក្នុងថង់ប្លាស្ទិកធំ ឬប្រអប់ក្រដាស់ធំមួយដែលបិទជិតរក្សាវាទុកក្នុងរណ្តៅនោះចំនួន ៣០ ថ្ងៃ នោះពងចង្រិតវានឹងញាស់ ។ កាលបើចង្រិតវាញាស់ហើយ



យើងត្រូវទិញចំណីកូនមាន់យកមកកិនឱ្យម៉ដ្ឋ ដាក់ទឹកក្នុងដបស្រ្ពេយ បាញ់ផ្សើមចំណីនោះគ្រាន់តែឱ្យសើមៗ រួចដាក់លាតនៅលើចានសំប៉ែតមួយចំនួនពង្រាយឱ្យបានច្រើនកន្លែង ដើម្បីឱ្យកូនចង្រិតវាស៊ី។ ឱ្យវាស៊ីតែចំណីនេះ ទាំងទើបញាស់រហូតដល់វាធំចាប់លក់ឬទុកពូជក្តី។

បើយើងទុកវាឱ្យដល់រយៈពេលពីរខែ ចង្រិតនឹងមានពង យើងប្រមូលយកពងនោះមកភ្ញាស់ខ្លះ អាចលក់ឱ្យគេបានខ្លះដើម្បីយកកម្រៃ ។ ទុកចង្រិតមួយចំនួនឱ្យវាពងជាលើកទីពីរ សឹមលក់វាចេញ យើងទុកតែពងវាសម្រាប់ភ្ញាស់បានហើយ ។

បន្ទាប់ពីវាពងលើកទីពីរហើយត្រូវចាប់លក់ចេញទាំងអស់ ភ្ញាស់សារជាថ្មីទៀត ។ ចង្រិតពងតែពីរដងទេក្នុងមួយជីវិតរបស់វា ។ ចង្រិតញីមានស្លាបលាត ឯចង្រិតឈ្មោលមានស្លាបក្រញ៉ាញ់។

យើងអាចពង្រីកមុខរបរនេះ ទៅតាមលទ្ធភាពដែលមានបាន ដោយស្តើរៗយើងអាចបង្កើនចំនួនពង ត្រូវភ្ញាស់ រហូតយើងអាចរកចំណូលបានគ្រប់គ្រាន់។

## អត្ថប្រយោជន៍នៃការចិញ្ចឹមចង្រិត ៖



- ងាយស្រួលចិញ្ចឹម
- ស៊ីចំណីតិចបំផុត
- អាចពង្រីកមុខរបរបាន
- មិនសូវមានការប្រជែងក្នុងទីផ្សារ
- អាចលក់បានក្នុងមួយគីឡូ ៦០០០ ទៅ ៨០០០ រៀលក្នុងមួយគីឡូ
- មិនត្រូវការថៃទាំច្រើន
- ត្រូវការទីកន្លែងមិនធំពេក
- អាចធ្វើបានគ្រប់គ្នា
- ការខាតបង់មានតិចតួចណាស់ បើសិនជាមាន
- អាចរកចំណូលបានច្រើន
- ប្រើពេលវេលាតិច ឆាប់បានទទួលផល
- យើងអាចយកវាធ្វើជាចំណីមាន់ទា ត្រី បើលក់មិនបាន

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)